# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
លេខ : ៤៣៥៣/២៣ អ គ រ

ថ្ងៃ ពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីលម្អិត និង ភារកិច្ចទទួលខុសត្រូវ នៃកិច្ចដំណើរការការរាយការណ៍អំពីទំនិញ និងកិច្ចដំណើរការប្រតិវេទន៍គយ តាមមធ្យោបាយអេឡិចត្រូនិក

អនុលោមតាមបញ្ញត្តិប្រកាសលេខ ១៨៤៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយ និងប្រកាសលេខ ៧៨៨ សហវ.ប្រក.អគរ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីបំពេញបែបបទគយមុនទំនិញមកដល់ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាសូមកំណត់នូវនីតិវិធីលម្អិត និង ភារកិច្ចទទួលខុសត្រូវរបស់មន្ត្រីគយនិងរដ្ឋាករ ប្រតិវេទករ ប្រតិបត្តិករដឹកជញ្ជូនទំនិញ ប្រតិបត្តិករបញ្ជូនទំនិញ ប្រតិបត្តិករនាវាភារវេទកិច្ច ប្រតិបត្តិករបញ្ញើរហ័ស និងអ្នកពាក់ព័ន្ធ ក្នុងកិច្ចដំណើរការនៃការរាយការណ៍អំពីទំនិញ និងកិច្ចដំណើរការប្រតិវេទន៍គយតាមប្រព័ន្ធស្វ័យប្រវត្តិកម្មគយ ដូចខាងក្រោម÷

## I. ការរាយការណ៍អំពីទំនិញ

រាល់ទំនិញចូលមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងនាំចូលឬឆ្លងកាត់ តាមគ្រប់ប្រភេទមធ្យោបាយដឹកជញ្ជូន ជាកម្មវត្ថុនៃការរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយ ក្នុងទម្រង់អេឡិចត្រូនិកមុនពេលទំនិញមកដល់។

### ក. កាតព្វកិច្ចរាយការណ៍អំពីទំនិញ

បុគ្គលដែលមានកាតព្វកិច្ចរាយការណ៍អំពីទំនិញ ត្រូវបានកំណត់ដូចខាងក្រោម÷

- ប្រតិបត្តិករដឹកជញ្ជូនទំនិញ (Carrier) មានកាតព្វកិច្ចរាយការណ៍អំពីទំនិញក្នុងទម្រង់អេឡិចត្រូនិក នូវទិន្នន័យនិវេទនបណ្ណទំនិញ អញ្ញត្តបណ្ណ និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល រួមទាំងព័ត៌មានស្ថានភាពកុងតឺន័រ
- ប្រតិបត្តិករបញ្ជូនទំនិញ (Freight Forwarder) និងប្រតិបត្តិករនាវាភារវេទកិច្ច (NVOCC) មានកាតព្វកិច្ចរាយការណ៍អំពីទំនិញក្នុងទម្រង់អេឡិចត្រូនិក នូវទិន្នន័យអញ្ញត្តបណ្ណមេ(បើមាន) អញ្ញត្តបណ្ណរង និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល


អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

- ប្រតិបត្តិករបញ្ញើរហ័ស (Express Courier) មានកាតព្វកិច្ចរាយការណ៍អំពីទំនិញក្នុងទម្រង់អេឡិចត្រូនិក នូវទិន្នន័យនិវេទនបណ្ណទំនិញ(បើមាន) អញ្ញាតបណ្ណ និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល។

បុគ្គលរាយការណ៍អំពីទំនិញ អាចប្រើប្រាស់ភ្នាក់ងារតំណាងដើម្បីរាយការណ៍អំពីទំនិញជំនួស ដោយត្រូវជូនដំណឹងជាមុនដល់រដ្ឋបាលគយ អំពីការផ្តល់សិទ្ធិ ការផ្លាស់ប្តូរ ការបន្ថែម ឬការបញ្ឈប់ភ្នាក់ងារតំណាងរបស់ខ្លួន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលរាយការណ៍អំពីទំនិញ ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវនៃការរាយការណ៍អំពីទំនិញ ទោះបីជាការរាយការណ៍ត្រូវបានធ្វើឡើងដោយខ្លួនឯង ឬដោយភ្នាក់ងារតំណាងក៏ដោយ។

## ខ. ពេលវេលានៃការរាយការណ៍អំពីទំនិញ

ពេលវេលានៃការរាយការណ៍អំពីទំនិញ ត្រូវបានកំណត់ដូចខាងក្រោម÷

១. ការដឹកជញ្ជូនតាមផ្លូវទឹក

- ចំពោះទំនិញដែលផ្ទុកក្នុងកុងតឺន័រ ត្រូវរាយការណ៍មិនយឺតជាង ២៤(ម្ភៃបួន)ម៉ោង មុនពេលផ្ទុកក្នុងនាវា នៅកំពង់ផែចេញដំណើរចុងក្រោយ
- ចំពោះទំនិញចាក់ធារ ទំនិញរាយមិនផ្ទុកក្នុងកុងតឺន័រ និងទំនិញជាវត្ថុធាតុរាវ ត្រូវរាយការណ៍មិនយឺតជាង ២៤(ម្ភៃបួន)ម៉ោង មុនពេលទំនិញមកដល់កំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា។

២. ការដឹកជញ្ជូនតាមផ្លូវអាកាស

- ត្រូវរាយការណ៍មុនពេលអាកាសយានចាកចេញពីអាកាសយានដ្ឋានចេញដំណើរនៅបរទេស។

៣. ការដឹកជញ្ជូនតាមផ្លូវគោក

- ចំពោះទំនិញដឹកតាមរថយន្ត ត្រូវរាយការណ៍មិនយឺតជាង ១(មួយ)ម៉ោង មុនពេលមកដល់មាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- ចំពោះទំនិញដឹកតាមរថភ្លើង ត្រូវរាយការណ៍មិនយឺតជាង ២(ពីរ)ម៉ោង មុនពេលមកដល់មាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។

## គ. កិច្ចដំណើរការនៃការរាយការណ៍អំពីទំនិញ

ការរាយការណ៍អំពីទំនិញតាមមធ្យោបាយអេឡិចត្រូនិក ត្រូវបានប្រព្រឹត្តិទៅដូចខាងក្រោម÷

- បុគ្គលដែលមានកាតព្វកិច្ចត្រូវរាយការណ៍អំពីទំនិញឬតំណាងត្រូវបញ្ជូនទិន្នន័យដោយត្រង់ពីប្រព័ន្ធអេឡិចត្រូនិករបស់ខ្លួនមកកាន់ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (System to System) ឬបញ្ចូលទិន្នន័យមកក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មគយដោយផ្ទាល់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ“ក” នៃសេចក្តីណែនាំនេះ
- បុគ្គលរាយការណ៍អំពីទំនិញអាចកែតម្រូវឬលុបទិន្នន័យនៃការរាយការណ៍អំពីទំនិញរបស់ខ្លួន នៅ

តេឡេក្រាម ឯកសារផ្លូវការ: - https://t.me/oa_channel

មុនពេលទំនិញមកដល់។ ចំពោះព័ត៌មាននិងទិន្នន័យចុងក្រោយនៃការរាយការណ៍អំពីទំនិញ ត្រូវចាត់ទុកជាផ្លូវការ ពេលទំនិញមកដល់។ ក្រោយពេលទំនិញមកដល់ ប្រសិនបើបុគ្គលខាងលើមានបំណងចង់កែតម្រូវព័ត៌មាននិងទិន្នន័យនៃការរាយការណ៍អំពីទំនិញ ត្រូវស្នើសុំទៅមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច ដោយត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់។ ការកែតម្រូវនេះ អាចត្រូវបានអនុញ្ញាតក្នុងករណីពិនិត្យឃើញថាសមស្រប និងពុំបំពានលើបទប្បញ្ញត្តិជាធរមាន

- ក្រោយកាលបរិច្ឆេទប៉ាន់ស្មានមកដល់ ១០(ដប់)ថ្ងៃយ៉ាងយូរ ប្រសិនបើទំនិញឬមធ្យោបាយដឹកជញ្ជូនមិនមកដល់ឬត្រូវពន្យារពេល ប្រតិបត្តិករត្រូវជូនដំណឹងមករដ្ឋបាលគយ ដូចខាងក្រោម÷
  - ប្រតិបត្តិករដឹកជញ្ជូនទំនិញត្រូវជូនដំណឹងមករដ្ឋបាលគយ ក្នុងករណីមធ្យោបាយដឹកជញ្ជូនមិនមកដល់ឬត្រូវពន្យារពេល
  - ប្រតិបត្តិករបញ្ជូនទំនិញ ប្រតិបត្តិករនាវាភារវេទកិច្ច ឬប្រតិបត្តិករបញ្ញើរហ័ស ត្រូវជូនដំណឹងមករដ្ឋបាលគយ ក្នុងករណីទំនិញដែលខ្លួនបានរាយការណ៍ មិនមកដល់ឬត្រូវពន្យារពេល។

អញ្ញាតបណ្ណមេនឹងត្រូវបានធ្វើការផ្ទៀងផ្ទាត់ (De-groupage) ដោយស្វ័យប្រវត្តិ ប្រសិនបើទិន្នន័យអញ្ញាតបណ្ណរងមានសង្គតិភាពជាមួយគ្នា។ ទម្រង់ តម្រូវការ និងកំណត់ពន្យល់នានា នៃការរាយការណ៍អំពីនិវេទនបណ្ណ និងការរាយការណ៍អំពីអញ្ញាតបណ្ណ មានកំណត់ក្នុងឧបសម្ព័ន្ធ "ខ" នៃសេចក្តីណែនាំនេះ។

## ឃ. ភារកិច្ចរបស់មន្ត្រីគយគ្រប់គ្រងការរាយការណ៍អំពីទំនិញ

មន្ត្រីគយគ្រប់គ្រងការរាយការណ៍អំពីទំនិញ មានភារកិច្ចដូចខាងក្រោម÷

- ពិនិត្យនិងផ្ទៀងផ្ទាត់ការប្រកាសរាយការណ៍អំពីទំនិញ រួមមាន និវេទនបណ្ណទំនិញ អញ្ញាតបណ្ណមេ អញ្ញាតបណ្ណរង និង/ឬឯកសារផ្សេងទៀតក្នុងទម្រង់ប្រហាក់ប្រហែល រួមទាំងព័ត៌មានផ្សេងទៀត ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (ថ្នាលអាស៊ីហាប់)
- វាយតម្លៃហានិភ័យលើការរាយការណ៍អំពីទំនិញ ក្នុងករណីរកឃើញភាពមិនប្រក្រតីនានាឬពិនិត្យឃើញថា ទំនិញត្រូវហាមឃាត់ដាច់ខាត ត្រូវផ្តល់មូលវិចារណ៍ក្នុងប្រព័ន្ធ រួចត្រូវរាយការណ៍ជូនប្រធានអង្គភាព ដើម្បីជ្រាបនិងមានវិធានការបន្ត
- គ្រប់គ្រង និងសម្របសម្រួលលើកិច្ចដំណើរការផ្ញើកូដសារជូនដំណឹង ប្រសិនបើមានការសម្រេចឱ្យដាក់វិធានណាមួយ ដូចខាងក្រោម÷
  - កូដ HLD (Hold)÷ ក្នុងករណីតម្រូវឱ្យអ្នករាយការណ៍ត្រូវផ្តល់ព័ត៌មានបន្ថែមឬកែតម្រូវព័ត៌មានដើម្បីអាចឱ្យប្រព័ន្ធវាយតម្លៃហានិភ័យបានពេញលេញ
  - កូដ DNU (Do Not Unload)÷ ក្នុងករណីរកឃើញថា ទំនិញជាប្រភេទហាមឃាត់ដាច់ខាត

ដោយមិនអនុញ្ញាតឱ្យផ្ទេរទំនិញចេញពីមធ្យោបាយដឹកជញ្ជូន ចូលមកក្នុងដែនគយនៃព្រះរាជា-ណាចក្រកម្ពុជា

- កូដ SPD (Suspend)÷ ក្នុងករណីប្រតិបត្តិករមិនបានរាយការណ៍អំពីទំនិញទាន់ពេលវេលា និងលក្ខខណ្ឌតម្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

- ត្រូវបានកំណត់កាលបរិច្ឆេទមកដល់នៃទំនិញ ដូចខាងក្រោម÷
  - ចំពោះការដឹកជញ្ជូនតាមផ្លូវទឹក÷ ត្រូវកំណត់យកតាមកាលបរិច្ឆេទនៃទម្រង់ការបែបបទនាវា
  - ចំពោះការដឹកជញ្ជូនតាមផ្លូវអាកាស÷ ត្រូវកំណត់យកតាមកាលបរិច្ឆេទ ដែលទំនិញដាក់ចូលក្នុងសន្និធិគយបណ្តោះអាសន្ន
  - ចំពោះការដឹកជញ្ជូនតាមផ្លូវគោក÷ ត្រូវកំណត់យកតាមកាលបរិច្ឆេទ ដែលទំនិញមកដល់មាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
- ក្នុងករណីទំនិញឬមធ្យោបាយដឹកជញ្ជូនមិនមកដល់ឬមានសេចក្តីសម្រេចផ្សេងទៀត មន្ត្រីគយគ្រប់គ្រងការរាយការណ៍អំពីទំនិញអាចធ្វើការកែតម្រូវឬលុបព័ត៌មានឬទិន្នន័យនៃការរាយការណ៍អំពីទំនិញចេញពីប្រព័ន្ធ
- ក្នុងករណីចំនួនភណ្ឌិកាឬទម្ងន់ទំនិញជាក់ស្តែងតិចឬច្រើនជាងបរិមាណទំនិញដែលបានរាយការណ៍ក្នុងអញ្ញាតបណ្ណរង មន្ត្រីគយគ្រប់គ្រងការរាយការណ៍អំពីទំនិញអាចធ្វើការកែតម្រូវទិន្នន័យទាំងនេះក្នុងមុខងារ Excess/Shortage នៃប្រព័ន្ធអាស៊ីគូដា
- ទំនិញដែលបានបំពេញបែបបទគយរួច នឹងត្រូវកាត់ចេញពីទិន្នន័យបញ្ជីសន្និធិទំនិញដោយស្វ័យប្រវត្តិ។ បន្ថែមពីនេះ មន្ត្រីគយគ្រប់គ្រងការរាយការណ៍អំពីទំនិញត្រូវធ្វើការកាត់ចេញពីបញ្ជីសន្និធិទំនិញ (Manual Write-Off) ក្នុងប្រព័ន្ធអាស៊ីគូដា ចំពោះទំនិញដែលស្ថិតក្នុងលក្ខខណ្ឌផ្សេងទៀត ដូចខាងក្រោម÷
  - ទំនិញគ្មានការទាមទារ ដែលបានលក់ដេញថ្លៃ យកធ្វើជាអំណោយឬកម្ទេចចោលរួចរាល់
  - ទំនិញនាំចូលដែលមិនទាន់បានបំពេញបែបបទបញ្ចេញទំនិញ ប៉ុន្តែត្រូវនាំចេញត្រឡប់ទៅវិញ
  - ទំនិញស្ថិតក្នុងលក្ខខណ្ឌផ្សេងទៀត ក្នុងករណីដែលមានសំអាងគ្រប់គ្រាន់។
- សម្របសម្រួលឬពន្យល់ណែនាំដល់ប្រតិបត្តិករ ក្នុងករណីប្រតិបត្តិករមានចម្ងល់ពាក់ព័ន្ធនឹងរបៀបរាយការណ៍អំពីទំនិញ
- គ្រប់គ្រង តាមដាន និងចងក្រងទិន្នន័យនៃបញ្ជីសន្និធិគយបណ្តោះអាសន្នទំនិញ ព្រមទាំងគ្រប់គ្រងទំនិញស្តុកទុកយូរ និងទំនិញគ្មានការទាមទារ។

## II. កិច្ចដំណើរការប្រតិវេទន៍គយ

### ក. ភារកិច្ចរបស់ប្រតិវេទករ (Declarant)

ប្រតិវេទករមានភារកិច្ច ដូចខាងក្រោម÷

### ១. ការដាក់ប្រតិវេទន៍គយ

- បញ្ចូលទិន្នន័យប្រតិវេទន៍គយ និង ពិនិត្យផ្ទៀងផ្ទាត់គ្រប់ប្រអប់ព័ត៌មាន ព្រមទាំងផ្ទុក(Upload) ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិក រួចចុះបញ្ជិកាប្រតិវេទន៍គយ (SAD) ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា)។ ឯកសារគាំទ្រត្រូវផ្ទុកក្នុងប្រព័ន្ធ ដើម្បីអមភ្ជាប់ប្រតិវេទន៍គយ រួមមាន វិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ និងអញ្ញាតបណ្ណ ជាដើម។ ក្នុងករណីចាំបាច់ អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនប័ត្រដើមកំណើត វិញ្ញាបនប័ត្រធានារ៉ាប់រង និងឯកសារពាក់ព័ន្ធផ្សេងទៀត ក៏ត្រូវផ្ទុកផងដែរ។ ចំពោះរាល់ឯកសារគាំទ្រដែលបានផ្ទុក និងឯកសារដែលបានអនុម័តរួចរាល់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិឬប្រព័ន្ធស្វ័យប្រវត្តិកម្មគយ ពុំតម្រូវឱ្យផ្ទុកអមភ្ជាប់ប្រតិវេទន៍គយឡើងវិញឡើយ។ ក្នុងកិច្ចដំណើរការប្រតិវេទន៍គយ ឯកសារគាំទ្រពុំតម្រូវឱ្យបកប្រែទេ លើកលែងតែក្នុងករណីចាំបាច់។ ប្រតិវេទន៍គយពុំតម្រូវឱ្យបោះពុម្ពជាទម្រង់ក្រដាស ដើម្បីដាក់ជូនរដ្ឋបាលគយឡើយ។
- ប្រតិវេទករត្រូវត្រៀមខ្លួនសម្រាប់ចូលរួមនៅពេលមានការត្រួតពិនិត្យរូបវន្តទំនិញ និងត្រូវត្រៀមឆ្លើយចំពោះសំណួរណាមួយដែលត្រូវបានសួរដោយមន្ត្រីគយក្នុងករណីចាំបាច់
- ប្រសិនបើត្រូវការកែតម្រូវឬលុបប្រតិវេទន៍គយ ប្រតិវេទករត្រូវទាក់ទងទៅមន្ត្រីគយសាកសួរ (Query)។ ក្នុងករណីមានចម្ងល់ពាក់ព័ន្ធនឹងការរៀបចំប្រតិវេទន៍ ប្រតិវេទករអាចស្នើសុំមន្ត្រីគយផ្តល់ជំនួយ (Help Desk) ដើម្បីពន្យល់ណែនាំ ប្រសិនបើចាំបាច់
- ក្នុងករណីប្រតិវេទន៍គយស្ថិតក្នុងច្រកប្រព្រឹត្តិកម្មក្រហម ប្រតិវេទករឬម្ចាស់ទំនិញត្រូវទាក់ទងទៅមន្ត្រីគយត្រួតពិនិត្យដោយម៉ាស៊ីនស្កេន(បើមាន)ដើម្បីធ្វើការស្កេនទំនិញ និងមន្ត្រីគយផ្នែកត្រួតពិនិត្យរូបវន្ត ដើម្បីធ្វើការត្រួតពិនិត្យរូបវន្តទំនិញ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ក្រោយពីការវាយតម្លៃចុងក្រោយ (Final Assessment) រួចរាល់ ប្រតិវេទករ ម្ចាស់ទំនិញឬតំណាងម្ចាស់ទំនិញត្រូវបានអនុញ្ញាតឱ្យធ្វើការបង់ពន្ធ អាករ និង/ឬកម្រៃផ្សេងៗ តាមជម្រើសដូចខាងក្រោម÷
    - ការទូទាត់តាមមធ្យោបាយអេឡិចត្រូនិក (E-Payment) ÷ ត្រង់ផ្នែក B នៃប្រតិវេទន៍គយ ត្រូវជ្រើសរើសពាក្យ "ONLINE PAYMENT" រួចធ្វើការទូទាត់តាមមធ្យោបាយអេឡិចត្រូនិកជាមួយធនាគារដៃគូ
    - ការទូទាត់តាមរយៈផ្ទេរឬដាក់ប្រាក់នៅធនាគារដៃគូ÷ ត្រង់ផ្នែក B នៃប្រតិវេទន៍គយ ត្រូវ

ជ្រើសរើសពាក្យ “BANK TRANSFER” រួចធ្វើការផ្ទេរប្រាក់ (Bank Transfer ឬ KHQR) ឬអាចដាក់ប្រាក់ដោយផ្ទាល់ទៅគណនីចំណូលរបស់អង្គភាពគយដែលដាក់ប្រតិវេទន៍ (Bank Deposit)។ ក្រោយធ្វើប្រតិបត្តិការផ្ទេរឬដាក់ប្រាក់រួចរាល់ ប្រតិវេទករត្រូវធ្វើការផ្ទុក (Upload) ឯកសារបញ្ជាក់ប្រតិបត្តិការទូទាត់ (Transaction Details ឬ Bank Slip) ចូលក្នុងប្រព័ន្ធអាស៊ីគូដា

- ការទូទាត់តាមគណនីបង់ប្រាក់ជាមុន (Pre-Payment)៖ ត្រូវបំពេញនូវលេខគណនីធនាគាររបស់ប្រតិវេទករក្នុងប្រអប់លេខ ៤៨ នៃប្រតិវេទន៍គយ។ ក្រោយទទួលបានការអនុញ្ញាតឱ្យទូទាត់ ប្រព័ន្ធនឹងធ្វើការទូទាត់ដោយស្វ័យប្រវត្តិពីគណនីធនាគាររបស់ប្រតិវេទករ ប្រសិនបើគណនីមានសមតុល្យទឹកប្រាក់គ្រប់គ្រាន់
- ការទូទាត់ជាសាច់ប្រាក់ (Cash)៖ ត្រង់ផ្នែក B នៃប្រតិវេទន៍គយ ត្រូវជ្រើសរើសពាក្យ “CASH” និងបង់សាច់ប្រាក់ជូនមន្ត្រីគយបេឡា ដើម្បីបញ្ជាក់ការបង់ប្រាក់ទៅក្នុងប្រព័ន្ធអាស៊ីគូដា
- ការទូទាត់តាមទម្រង់ផ្សេងទៀត៖ ត្រូវអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

- ក្រោយពីបានទូទាត់ប្រាក់ពន្ធនិងអាករ បង្កាន់ដៃបង់ប្រាក់ និងប័ណ្ណបញ្ចេញទំនិញ នឹងត្រូវផ្តល់ជូនក្នុងទម្រង់អេឡិចត្រូនិក។ ក្នុងករណីប្រតិវេទករត្រូវការបង្កាន់ដៃបង់ប្រាក់ និង ប័ណ្ណបញ្ចេញទំនិញក្នុងទម្រង់ក្រដាស ប្រតិវេទករអាចបោះពុម្ពចេញដោយខ្លួនឯង និងពុំតម្រូវឱ្យមានហត្ថលេខា និងបោះត្រាពីមន្ត្រីគយឡើយ។ ដោយឡែក បង្កាន់ដៃបង្វិលសង និងបង្កាន់ដៃពន្ធយានយន្ត ប្រតិវេទករត្រូវទទួលយកពីមន្ត្រីគយបេឡាឬគណនេយ្យរៀងគ្នា ដោយពុំតម្រូវឱ្យមានហត្ថលេខា និងបោះត្រាពីមន្ត្រីគយឡើយ
- ក្រោយការអនុញ្ញាតឱ្យបញ្ចេញទំនិញពីគយ ប្រតិវេទករត្រូវស្នើសុំប័ណ្ណដឹកជញ្ជូនទំនិញក្នុងប្រព័ន្ធ ដើម្បីមន្ត្រីគ្រប់គ្រងស្តុកទំនិញពិនិត្យផ្ទៀងផ្ទាត់។ ប្រតិវេទករត្រូវប្រគល់ប័ណ្ណដឹកជញ្ជូនទំនិញជូនអ្នកបើកបរ សម្រាប់អមភ្ជាប់មធ្យោបាយដឹកជញ្ជូននីមួយៗក្នុងទម្រង់អេឡិចត្រូនិក (PDF) ឬទម្រង់ក្រដាស
- ប្រសិនបើមានការសម្រេចអនុញ្ញាតឱ្យធ្វើការបង្វិលសងវិញទាំងស្រុងឬភាគខ្លះនូវពន្ធនិងអាករដែលបានបង់រួច ប្រតិវេទករឬម្ចាស់ទំនិញត្រូវយកសេចក្តីសម្រេចអនុញ្ញាតបង្វិលសងច្បាប់ដើម អមដោយប្រតិវេទន៍គយ បង្កាន់ដៃពន្ធ និងឯកសារពាក់ព័ន្ធនានា ប្រគល់ជូនមន្ត្រីគយគណនេយ្យពិនិត្យផ្ទៀងផ្ទាត់ ដើម្បីឱ្យមន្ត្រីគយបេឡាបង្វិលសង ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ប្រតិវេទករអាចតាមដានស្ថានភាពនៃដំណើរការប្រតិវេទន៍របស់ខ្លួន តាមរយៈកម្មវិធីទូរស័ព្ទដៃឆ្លាតវៃសម្រាប់ធុរជន គេហទំព័រគយឬផ្ទាំងផ្តល់ព័ត៌មាននៅតាមអង្គភាពគយនីមួយៗ។ ព័ត៌មាននៃការអនុញ្ញាតឱ្យយកទំនិញចេញពីគយ នឹងត្រូវផ្តល់ជូនតាមរយៈប្រព័ន្ធអេឡិចត្រូនិក

- ប្រតិវេទករអាចបោះពុម្ពប្រតិវេទន៍គយទម្រង់ក្រដាស ក្នុងគោលបំណងសម្រាប់ប្រើប្រាស់របស់ខ្លួនតាមតម្រូវការចាំបាច់។ ប្រតិវេទករនិងម្ចាស់ទំនិញ ត្រូវរក្សាទុកប្រតិវេទន៍គយនិងរាល់ឯកសារពាក់ព័ន្ធក្នុងទម្រង់ក្រដាសឬទម្រង់អេឡិចត្រូនិក(ជា PDF ឬទម្រង់ផ្សេងទៀត) ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ប្រតិវេទករមិនត្រូវចែករំលែកព័ត៌មានឬផ្តល់គណនីប្រើប្រាស់របស់ខ្លួនទៅអ្នកដទៃជាដាច់ខាត។ ក្នុងករណីប្រតិវេទករឈប់ប្រើប្រាស់គណនីរបស់ខ្លួនជាអចិន្ត្រៃយ៍ ត្រូវបិទគណនីប្រើប្រាស់របស់ខ្លួនភ្លាម
- ពេលបញ្ចប់ប្រតិបត្តិការ ប្រតិវេទករត្រូវចាកចេញពីប្រព័ន្ធ (Logout)។ ក្នុងករណីប្រើប្រាស់កុំព្យូទ័រសាធារណៈឬកុំព្យូទ័រនៅបន្ទប់បញ្ចូលទិន្នន័យតាមអង្គភាពគយនីមួយៗ ប្រតិវេទករត្រូវលុបរាល់ឯកសាររបស់ខ្លួន និងសម្អាតធុងសម្រាម (Trash) ក្នុងកុំព្យូទ័រនោះ។

## ២. ការដាក់ប្រតិវេទន៍គយមុនពេលទំនិញមកដល់

- ក្រោយពីការរាយការណ៍អំពីទំនិញមានលក្ខណៈគ្រប់គ្រាន់ ប្រតិវេទករអាចដាក់ប្រតិវេទន៍គយមុនពេលទំនិញមកដល់ (Pre-Lodged SAD) ដោយភ្ជាប់ឯកសារគាំទ្រក្នុងទម្រង់អេឡិចត្រូនិកស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ប្រតិវេទន៍គយមុនពេលទំនិញមកដល់ នឹងត្រូវបានទទួលយកមកវាយតម្លៃហានិភ័យ និងត្រួតពិនិត្យឯកសារជាមុន។ ប្រតិវេទន៍គយមុនពេលទំនិញមកដល់ដែលបានវាយតម្លៃនិងត្រួតពិនិត្យរួច ពុំតម្រូវឱ្យត្រួតពិនិត្យឯកសារឡើងវិញឡើយនៅពេលទំនិញមកដល់ លើកលែងតែក្នុងករណីមានការកែតម្រូវឬរកឃើញថា មានហានិភ័យខ្ពស់
- ប្រតិវេទករអាចធ្វើការកែតម្រូវឬលុបប្រតិវេទន៍គយមុនពេលទំនិញមកដល់ដោយខ្លួនឯងនៅពេលដែលមន្ត្រីគយពុំទាន់បានទទួលយកមកពិនិត្យ។ ក្នុងករណីទំនិញមិនអាចមកដល់ ប្រតិវេទករត្រូវស្នើសុំលុបប្រតិវេទន៍គយមុនពេលទំនិញមកដល់នោះចេញពីប្រព័ន្ធ ដោយត្រូវបញ្ជាក់មូលហេតុជាក់លាក់
- ក្រោយពេលទំនិញមកដល់ “ប្រតិវេទន៍គយមុនពេលទំនិញមកដល់” នឹងត្រូវចុះបញ្ជីដោយស្វ័យប្រវត្តិទៅជា “ប្រតិវេទន៍គយ” ដែលជាកម្មវត្ថុនៃការអនុវត្តបន្តស្របតាមបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយជាធរមាន។

## ខ. ភារកិច្ចរបស់មន្ត្រីគយត្រួតពិនិត្យឯកសារ (Documentary Check)

មន្ត្រីគយត្រួតពិនិត្យឯកសារ មានភារកិច្ចដូចខាងក្រោម÷

- ពិនិត្យភាពគ្រប់គ្រាន់នៃ “ប្រតិវេទន៍គយ” ឬ “ប្រតិវេទន៍គយមុនពេលទំនិញមកដល់” និងឯកសារគាំទ្រក្នុងប្រព័ន្ធអាស៊ីគូដា រួមមាន វិក្កយបត្រ បញ្ជីវេចខ្ចប់ អាជ្ញាបណ្ណ និង/ឬឯកសារពាក់ព័ន្ធដែល

តម្រូវដទៃទៀត ព្រមទាំងផ្ទៀងផ្ទាត់ប្រាក់ពន្ធ អាករ និងកម្រៃផ្សេងៗ រួចបញ្ចាឱ្យប្រព័ន្ធអាស៊ីគូដាវាយតម្លៃហានិភ័យ និង ផ្តល់ច្រកពណ៌ប្រព្រឹត្តិកម្ម

- ពិនិត្យលក្ខណៈវិនិច្ឆ័យជ្រើសរើស (View Criteria) អំពីមូលហេតុដែលនាំឱ្យមានការជ្រើសរើសច្រកប្រព្រឹត្តិកម្មពណ៌សម្រាប់ប្រតិវេទន៍គយនោះ
- ពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មាននៃការរាយការណ៍អំពីទំនិញ ប្រៀបធៀបទៅនឹងប្រតិវេទន៍គយ
- ត្រួតពិនិត្យលើភាពត្រឹមត្រូវនៃទិន្នន័យប្រតិវេទន៍គយជាមួយឯកសារគាំទ្រ ដូចខាងក្រោម÷
  - ត្រួតពិនិត្យលម្អិត ចំពោះប្រតិវេទន៍គយដែលស្ថិតក្នុងច្រកប្រព្រឹត្តិកម្មពណ៌លឿងឬក្រហម
  - ត្រួតពិនិត្យសង្កេត ចំពោះប្រតិវេទន៍គយដែលស្ថិតក្នុងច្រកប្រព្រឹត្តិកម្មពណ៌បៃតងឬខៀវ។
- ការពិនិត្យឯកសារ ត្រូវធ្វើឱ្យបានចប់សព្វគ្រប់ពេញលេញ ដោយមិនត្រូវបញ្ឈប់ត្រឹមតែកំហុសទីមួយត្រូវបានរកឃើញនោះទេ
- ប្រតិវេទន៍គយមុនពេលទំនិញមកដល់ដែលបានត្រួតពិនិត្យរួចហើយ ប្រសិនបើគ្មានការកែតម្រូវណាមួយនៅក្រោយពេលទំនិញមកដល់ មិនតម្រូវឱ្យធ្វើការត្រួតពិនិត្យឡើងវិញទេ លើកលែងតែមានការតម្រូវដោយឡែក។ ប្រសិនបើ ប្រតិវេទន៍គយមុនពេលទំនិញមកដល់ត្រូវបានត្រួតពិនិត្យឯកសាររួចរាល់ ប៉ុន្តែមានការកែតម្រូវ នោះប្រតិវេទន៍គយត្រូវវាយតម្លៃហានិភ័យ ផ្តល់ច្រកពណ៌ប្រព្រឹត្តិកម្ម និងត្រួតពិនិត្យឡើងវិញ នៅពេលទំនិញមកដល់
- នៅពេលបញ្ចប់ការត្រួតពិនិត្យឯកសារ ត្រូវបំពេញលទ្ធផលត្រួតពិនិត្យក្នុងមុខងារ Selectivity Control Page នៃប្រព័ន្ធអាស៊ីគូដា ទោះជាលទ្ធផលត្រួតពិនិត្យឃើញថា ត្រឹមត្រូវឬមិនត្រឹមត្រូវក៏ដោយ។ ក្នុងករណីរកឃើញភាពមិនត្រឹមត្រូវ ត្រូវជ្រើសរើសយកកូដកំហុស ផ្តល់ព័ត៌មានសូចនាករដែលគួរកែតម្រូវ និងមូលវិចារណ៍ សម្រាប់មន្ត្រីគយសាកសួរ និង/ឬមន្ត្រីគយផ្នែកត្រួតពិនិត្យរូបវន្តក្នុងទម្រង់លទ្ធផលត្រួតពិនិត្យក្នុងមុខងារ Inspection Act នៃប្រព័ន្ធអាស៊ីគូដា។

## គ. ភារកិច្ចរបស់មន្ត្រីគយត្រួតពិនិត្យដោយម៉ាស៊ីនស្កេន (Scanning Examiner)

មន្ត្រីគយត្រួតពិនិត្យដោយម៉ាស៊ីនស្កេន មានភារកិច្ចដូចខាងក្រោម÷

- អនុវត្តកិច្ចប្រតិបត្តិការស្កេន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ធ្វើការវិភាគនិងវាយតម្លៃរូបភាពស្កេន ជាមួយប្រតិវេទន៍គយដែលបានប្រកាស
- បញ្ជាក់លទ្ធផលនៃការវិភាគរូបភាពស្កេននីមួយៗក្នុងប្រព័ន្ធ ទោះបីជាមានឬគ្មានការសង្ស័យក៏ដោយ។ ក្នុងករណីមានការសង្ស័យ ត្រូវចង្អុលបង្ហាញក្នុងប្រព័ន្ធ អំពីចំណុចដែលត្រូវត្រួតពិនិត្យរូបវន្ត និង/ឬព័ត៌មានសង្ស័យ
- ប្រតិវេទន៍គយមុនពេលទំនិញមកដល់ដែលស្ថិតក្នុងច្រកប្រព្រឹត្តិកម្មពណ៌ក្រហម ទំនិញអាចអនុញ្ញាតឱ្យឆ្លងកាត់ម៉ាស៊ីនស្កេនភ្លាមនៅពេលទំនិញមកដល់។

### ឃ. ភារកិច្ចរបស់មន្ត្រីគយផ្នែកត្រួតពិនិត្យរូបវន្ត (Physical Examiner)

មន្ត្រីគយផ្នែកត្រួតពិនិត្យរូបវន្ត មានភារកិច្ចដូចខាងក្រោម÷

- ទទួលការណាត់ជួបជាមួយប្រតិវេទករ ដើម្បីកំណត់ពេលវេលានិងទីកន្លែងត្រួតពិនិត្យរូបវន្តទំនិញ
- ធ្វើការត្រួតពិនិត្យរូបវន្តទំនិញ ចំពោះប្រតិវេទន៍គយស្ថិតក្នុងច្រកប្រព្រឹត្តិកម្មពណ៌ក្រហម ផ្អែកលើលក្ខណៈវិនិច្ឆ័យជ្រើសរើស ព័ត៌មានផ្តល់ពីមន្ត្រីគយត្រួតពិនិត្យដោយម៉ាស៊ីនស្កេន(បើមាន) ព័ត៌មាននានានិង/ឬមានការចង្អុលបង្ហាញផ្សេងទៀត ដោយមានមន្ត្រីគយចូលរួមយ៉ាងតិចចំនួនពីរនាក់ និងត្រូវមានវត្តមានប្រតិវេទករនិង/ឬម្ចាស់ទំនិញ
- នៅពេលបញ្ចប់ការត្រួតពិនិត្យរូបវន្តទំនិញ ទោះជាលទ្ធផលត្រួតពិនិត្យរកឃើញថា មានឬគ្មានភាពមិនប្រក្រតីក៏ដោយ ត្រូវបញ្ចូលលទ្ធផលត្រួតពិនិត្យក្នុងមុខងារ Selectivity Control Page ឬកម្មវិធីទូរស័ព្ទឆ្លាតវៃសម្រាប់មន្ត្រីគយត្រួតពិនិត្យ
- ក្នុងករណីរកឃើញភាពមិនប្រក្រតី ត្រូវអនុវត្តដូចខាងក្រោម÷
  - ត្រួតពិនិត្យរូបវន្តទំនិញលម្អិត ស្របតាមនីតិវិធីជាធរមាន
  - កត់ត្រាលទ្ធផលត្រួតពិនិត្យក្នុងមុខងារ Inspection Act ដោយត្រូវជ្រើសរើសកូដកំហុស ផ្តល់ព័ត៌មាន និង មូលវិចារណ៍ជាដើម
  - កសាងកំណត់ហេតុល្មើសច្បាប់គយស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងករណីនេះ ឯកសារពាក់ព័ន្ធនានាក្នុងទម្រង់ក្រដាសអាចតម្រូវឱ្យភ្ជាប់បន្ថែម និងឯកសារដែលបានផ្ទុកក្នុងប្រព័ន្ធអាចបោះពុម្ពចេញជាទម្រង់ក្រដាស តាមការចាំបាច់។
- ក្នុងករណីមានសេចក្តីសម្រេច ការចង្អុលបង្ហាញឬការស្នើសុំពីប្រតិវេទករឬម្ចាស់ទំនិញ មន្ត្រីគយផ្នែកត្រួតពិនិត្យរូបវន្តទំនិញអាចធ្វើការត្រួតពិនិត្យទំនិញជាក់ស្តែង ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- នៅពេលធ្វើការត្រួតពិនិត្យ មន្ត្រីគយអាចដកយកទំនិញគំរូ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ទំនិញគំរូដែលបានដកយក ពុំជាកម្មវត្ថុនៃការប្រកាសប្រតិវេទន៍គយដោយឡែកឡើយ។

### ង. ភារកិច្ចរបស់មន្ត្រីគយសាកសួរ (Query)

មន្ត្រីគយសាកសួរ មានភារកិច្ចដូចខាងក្រោម÷

- ទទួលជួបជាមួយប្រតិវេទករដើម្បីស្តាប់ការពន្យល់ សាកសួរបន្ថែមអំពីកំហុសឆ្គង ពិភាក្សាអំពីការកែតម្រូវប្រតិវេទន៍គយ និងអាចស្នើសុំបន្ថែមនូវឯកសារពាក់ព័ន្ធនានាក្នុងទម្រង់អេឡិចត្រូនិកឬទម្រង់ក្រដាស
- ប្រសិនបើមានការព្រមព្រៀងពីប្រតិវេទករ ត្រូវធ្វើការកែតម្រូវប្រតិវេទន៍គយដែលរកឃើញថា មាន

កំហុសឆ្គងពិតមែន រួចផ្តល់មូលវិចារណ៍អំពីការកែតម្រូវក្នុងមុខងារ Inspection Act។ ប្រសិនបើប្រតិវេទន៍គយមិនអាចកែតម្រូវបាន ត្រូវលុបប្រតិវេទន៍គយនោះចេញពីប្រព័ន្ធ តាមការស្នើសុំរបស់ប្រតិវេទករ។ ក្នុងករណី ប្រតិវេទករបានផ្តល់ភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីភាពត្រឹមត្រូវដែលអាចទទួលយកបាន នោះប្រតិវេទន៍គយពុំត្រូវកែតម្រូវទេ ប៉ុន្តែក៏ត្រូវផ្តល់មូលវិចារណ៍ឆ្លើយតបបញ្ជាក់អំពីលទ្ធផលនោះក្នុងមុខងារ Inspection Act ផងដែរ

- ប្រសិនបើមិនមានការព្រមព្រៀងពីប្រតិវេទករក្នុងការកែតម្រូវ ដោយផ្អែកតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានឬមិនទទួលបាននូវព័ត៌មានបន្ថែម មន្ត្រីគយសាកសួរត្រូវផ្តល់មូលវិចារណ៍ក្នុងមុខងារ Inspection Act ដោយបញ្ជាក់ហេតុផលនៃការមិនព្រមព្រៀងនោះ ដើម្បីមានវិធានការបន្ត
- នៅចុងថ្ងៃប្រតិបត្តិការនីមួយៗ មន្ត្រីគយសាកសួរ ត្រូវគ្រប់គ្រងនិងតាមដានប្រតិវេទន៍ដែលស្ថិតក្នុងស្ថានភាពមិនទាន់បញ្ចប់បែបបទគយ រួចរាយការណ៍ជូនប្រធានអង្គភាពប្រចាំថ្ងៃ ដើម្បីជំរុញប្រតិវេទករឱ្យប្រញាប់បញ្ចប់បែបបទរបស់ខ្លួន និងត្រូវរៀបចំរបាយការណ៍ប្រចាំខែ តាមការតម្រូវ។

**ច. ភារកិច្ចប្រធានត្រួតពិនិត្យ** (Chief Examiner)

ប្រធានត្រួតពិនិត្យ មានភារកិច្ចដូចខាងក្រោម÷

- ពិនិត្យមើលការរាយការណ៍ពីលទ្ធផលត្រួតពិនិត្យ និង មូលវិចារណ៍នានា របស់មន្ត្រីគយគ្រប់ផ្នែកដែលត្រូវរាយការណ៍ក្នុងប្រព័ន្ធថា បានបំពេញការងារស្របតាមលក្ខណៈវិនិច្ឆ័យជ្រើសរើស និងបានផ្តល់លទ្ធផលត្រួតពិនិត្យគ្រប់គ្រាន់
- ក្រោយពីទទួលបានរបាយការណ៍លទ្ធផលត្រួតពិនិត្យគ្រប់គ្រាន់ ប្រធានត្រួតពិនិត្យត្រូវអនុវត្តដូចខាងក្រោម÷
  - ករណីលទ្ធផលត្រួតពិនិត្យឃើញថា មិនមានភាពមិនប្រក្រតី÷
    1. ចំពោះប្រតិវេទន៍គយ ត្រូវប្តូរច្រកប្រតិវេទន៍គយទៅពណ៌បៃតង (Re-route to Green) និងបញ្ជាឱ្យប្រព័ន្ធអាស៊ីគូដាវាយតម្លៃចុងក្រោយ (Final Assessment)
    2. ចំពោះប្រតិវេទន៍គយមុនពេលទំនិញមកដល់ ដែលស្ថិតក្នុងច្រកប្រព្រឹត្តិកម្មពណ៌បៃតង ពណ៌ខៀវ និងពណ៌លឿង ត្រូវប្តូរច្រកប្រតិវេទន៍គយទៅពណ៌បៃតង ដើម្បីដាក់ឱ្យស្ថិតក្នុងការរង់ចាំនិងវាយតម្លៃចុងក្រោយនៅពេលទំនិញមកដល់។
  - ករណីលទ្ធផលត្រួតពិនិត្យឯកសាររកឃើញថា មានភាពមិនប្រក្រតី ត្រូវបញ្ជូនប្រតិវេទន៍គយឬប្រតិវេទន៍គយមុនពេលទំនិញមកដល់ទៅកាន់មន្ត្រីគយសាកសួរ (Re-route to Query) និងអាចផ្តល់យោបល់បន្ថែម ប្រសិនបើចាំបាច់។ ក្រោយពីមន្ត្រីគយសាកសួរធ្វើការកែតម្រូវឬផ្តល់មតិត្រឡប់មកវិញ ដោយពិនិត្យឃើញថាសមស្រប ត្រូវប្តូរច្រកប្រតិវេទន៍គយទៅពណ៌បៃតងនិងបញ្ជាឱ្យប្រព័ន្ធអាស៊ីគូដាវាយតម្លៃចុងក្រោយ ចំពោះច្រកប្រព្រឹត្តិកម្មពណ៌បៃតង ខៀវ និងលឿង។

ដោយឡែក ចំពោះច្រកប្រព្រឹត្តិកម្មពណ៌ក្រហម ត្រូវរង់ចាំលទ្ធផលត្រួតពិនិត្យរូបវន្តទំនិញ។

- ករណីលទ្ធផលត្រួតពិនិត្យរូបវន្តទំនិញឃើញថា មានភាពមិនត្រឹមត្រូវ ត្រូវរង់ចាំសេចក្ដីសម្រេចវិនិច្ឆ័យបទល្មើសគយ រួចបញ្ជូនប្រតិវេទន៍គយទៅកាន់មន្ត្រីគយសាកសួរកែតម្រូវប្រតិវេទន៍គយស្របតាមសេចក្ដីសម្រេចវិនិច្ឆ័យ។

- ក្នុងករណីដែលមានព័ត៌មានហានិភ័យកំណត់ដោយមន្ត្រីគយ ប្រធានត្រួតពិនិត្យអាចប្ដូរច្រកប្រព្រឹត្តិកម្មទៅពណ៌លឿងឬក្រហម
- ក្នុងករណីមានសេចក្ដីសម្រេចឱ្យធ្វើនិយ័តកម្មឬសងបែបបទគយ ប្រធានត្រួតពិនិត្យអាចបញ្ជូនប្រតិវេទន៍គយទៅមន្ត្រីគយសាកសួរ ដើម្បីធ្វើនិយ័តកម្ម
- ក្នុងករណីមានការកែតម្រូវការរាយការណ៍អំពីទំនិញ ប្រតិវេទន៍គយមុនពេលទំនិញមកដល់ ប្រតិវេទន៍គយឬការកែតម្រូវផ្សេងទៀត ប្រធានត្រួតពិនិត្យអាចបញ្ជូនប្រតិវេទន៍គយទៅមន្ត្រីគយត្រួតពិនិត្យឯកសារឱ្យត្រួតពិនិត្យឡើងវិញ និង/ឬមន្ត្រីគយត្រួតពិនិត្យរូបវន្តទំនិញ ដើម្បីត្រួតពិនិត្យទំនិញជាក់ស្ដែង ប្រសិនបើពិនិត្យឃើញថា ការកែតម្រូវនោះមានកម្រិតហានិភ័យខ្ពស់
- ក្រោយពេលទំនិញមកដល់ ប្រសិនបើលទ្ធផលត្រួតពិនិត្យក្នុងប្រព័ន្ធអាស៊ីគូដាត្រូវបានផ្ដល់គ្រប់គ្រាន់និងពុំមានភាពមិនប្រក្រតីណាមួយ ក្នុងរយៈពេល ៦០(ហុកសិប)នាទី ប្រព័ន្ធអាស៊ីគូដានឹងប្ដូរច្រកប្រតិវេទន៍គយទៅពណ៌បៃតង និងវាយតម្លៃចុងក្រោយដោយស្វ័យប្រវត្តិ។

### ឆ. **ភារកិច្ចរបស់មន្ត្រីគយបេឡា** (Cashier)

មន្ត្រីគយបេឡាមានភារកិច្ច ដូចខាងក្រោម÷

- បង្កើតដីកាទូទាត់ (Payment Advice) ចំពោះប្រតិវេទន៍គយដែលបានវាយតម្លៃចុងក្រោយរួចរាល់ដើម្បីផ្ដល់ព័ត៌មានជូនប្រតិវេទករ អំពីចំនួនទឹកប្រាក់ពន្ធ អាករ និងកម្រៃគ្រប់ប្រភេទដែលត្រូវទូទាត់
- នៅពេលមានការទូទាត់ប្រាក់ពន្ធអាករនិងកម្រៃគ្រប់ប្រភេទ មន្ត្រីគយបេឡាត្រូវអនុវត្តដូចខាងក្រោម÷
  - ការទូទាត់តាមមធ្យោបាយអេឡិចត្រូនិក÷ ផ្ទៀងផ្ទាត់ប្រតិបត្តិការដែលបានទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក
  - ការទូទាត់តាមរយៈផ្ទេរឬដាក់ប្រាក់÷ ផ្ទៀងផ្ទាត់ប្រតិបត្តិការដែលបានទូទាត់ រួចបង្កើតបង្កាន់ដៃបង់ប្រាក់ក្នុងប្រព័ន្ធអាស៊ីគូដា
  - ការទូទាត់តាមគណនីបង់ប្រាក់ជាមុន÷ ផ្ទៀងផ្ទាត់ប្រតិបត្តិការដែលបានទូទាត់
  - ការទូទាត់ជាសាច់ប្រាក់÷ ផ្ទៀងផ្ទាត់និងទទួលយកសាច់ប្រាក់ពីប្រតិវេទករ រួចបង្កើតបង្កាន់ដៃបង់ប្រាក់ក្នុងប្រព័ន្ធអាស៊ីគូដា
  - ការទូទាត់តាមទម្រង់ផ្សេងទៀត÷ ត្រូវអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បង្កាន់ដៃបង់ប្រាក់ពុំតម្រូវឱ្យបោះពុម្ព ចុះហត្ថលេខា និងបោះត្រាដោយមន្ត្រីគយឡើយ។

- ប្រសិនបើមានការអនុញ្ញាតឱ្យធ្វើការបង្វិលសងវិញទាំងស្រុងឬភាគខ្លះនូវពន្ធ អាករ និងកម្រៃដែលបានបង់រួច ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ត្រូវយោងឯកសារចាំបាច់នានា រួមមាន សេចក្តីសម្រេចច្បាប់ដើម ប្រតិវេទន៍គយ បង្កាន់ដៃបង់ប្រាក់ និង/ឬឯកសារពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើការបង្វិលសង រួចបង្កើតបង្កាន់ដៃបង្វិលសង (Refund) ក្នុងប្រព័ន្ធអាស៊ីគូដា ហើយបោះពុម្ពចំនួន ២(ពីរ)ច្បាប់ ដើម្បីឱ្យប្រតិវេទករចុះហត្ថលេខាទទួលស្គាល់ការបង្វិលសង។ បង្កាន់ដៃបង្វិលសងត្រូវរក្សាទុកចំនួន ១(មួយ)ច្បាប់ និងប្រគល់ជូនប្រតិវេទករចំនួន ១(មួយ)ច្បាប់
- ក្នុងករណីតម្រូវឱ្យមានការបង់បន្ថែមប្រាក់ពន្ធ អាករ និងកម្រៃ ត្រូវទទួលយកការបង់បន្ថែមពីប្រតិវេទករ រួចបង្កើតបង្កាន់ដៃបង់បន្ថែម (Other Payment) ក្នុងប្រព័ន្ធអាស៊ីគូដា។ ប្រសិនបើមានការសម្រេចនិងអនុញ្ញាតឱ្យធ្វើការបង្វិលសងចំពោះបង្កាន់ដៃបង់ពន្ធបន្ថែមដែលបានបង្កើតរួច មន្ត្រីគយបេឡាត្រូវចេញបង្កាន់ដៃបង្វិលសងផ្សេងទៀត (Other Refund) ក្នុងប្រព័ន្ធអាស៊ីគូដា
- នៅចុងវេននៃបេឡាករនីមួយៗ ត្រូវបោះពុម្ពបញ្ជីគណនេយ្យបណ្តោះអាសន្ន “បញ្ជីគណនេយ្យតាមមធ្យោបាយទូទាត់” ដើម្បីបញ្ជាក់ថា ចំនួនទឹកប្រាក់សរុបដែលទទួលបាន ដូចជា ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក សាច់ប្រាក់ សក្ខីបត្រធនាគារ សក្ខីបត្រឥណទានផ្សេងទៀតទាំងអស់ក្នុងវេនផ្ទៀងផ្ទាត់គ្នាជាមួយនឹងកំណត់ត្រាបង់ប្រាក់
- ផ្តល់បញ្ជីគណនេយ្យបណ្តោះអាសន្ន “បញ្ជីគណនេយ្យតាមមធ្យោបាយទូទាត់” សរុបចំនួនទឹកប្រាក់ទទួលបានក្នុងវេនដែលបេឡាករប្រមូលបាន និងសរុបចំនួនប្រតិវេទន៍គយទាំងអស់ដែលបានទូទាត់ប្រាក់ពន្ធរួចរាល់ ទៅឱ្យមន្ត្រីគយគណនេយ្យ។ ប្រសិនបើមិនស៊ីគ្នារវាងបញ្ជីគណនេយ្យ និងទឹកប្រាក់ដែលទទួលបាន ត្រូវរៀបចំរបាយការណ៍កែសម្រួល ហើយបញ្ជូនទៅឱ្យមន្ត្រីគយគណនេយ្យ
- អង្គភាពគយនិងរដ្ឋាករនីមួយៗ ត្រូវបិទផ្សាយលេខគណនីចំណូលរបស់ខ្លួននៅបញ្ជរព័ត៌មាន។

### ៥. ភារកិច្ចរបស់មន្ត្រីគយគណនេយ្យ (Accountant)

មន្ត្រីគយគណនេយ្យមានភារកិច្ច ដូចខាងក្រោម÷

- ផលិតរបាយការណ៍គណនេយ្យនៅរៀងរាល់ចុងថ្ងៃប្រតិបត្តិការ រួមមាន បញ្ជីគណនេយ្យតាមប្រភេទប្រតិបត្តិការ បញ្ជីគណនេយ្យតាមបែបផែនទូទាត់ បញ្ជីគណនេយ្យតាមគណនីថវិកា និងរបាយការណ៍គណនេយ្យផ្សេងទៀត តាមការតម្រូវ
- ពិនិត្យរបាយការណ៍ប្រចាំថ្ងៃពីធនាគារដៃគូទទួលបានការអនុញ្ញាត ដែលមានការបញ្ជាក់ឬកំណត់ត្រាកិច្ចប្រតិបត្តិការ រួចកត់ត្រាបញ្ចូលទៅក្នុងគណនីរបស់គយ
- ប្រៀបធៀបរបាយការណ៍ប្រចាំថ្ងៃរបស់ធនាគារ ជាមួយនឹងសក្ខីបត្រធនាគារដែលបេឡាករផ្តល់ជូន។ ក្នុងករណីមិនស៊ីគ្នារវាងសក្ខីបត្រដែលបេឡាករបញ្ជាក់ជូន និងរបាយការណ៍ប្រចាំថ្ងៃរបស់ធនាគារ

ត្រូវធ្វើរបាយការណ៍ជូនប្រធានអង្គភាព ដើម្បីមានវិធានការបន្ត

- នៅចុងខែនីមួយៗ បោះពុម្ពបញ្ជីគណនេយ្យប្រចាំខែ (តាមបែបផែនប្រតិបត្តិការ តាមបែបផែនទូទាត់ និងតាមគណនីថវិកា) និងរបាយការណ៍ផ្សេងទៀត តាមការតម្រូវ
- ចំពោះទំនិញជាប្រភេទយានយន្តដែលតម្រូវឱ្យចេញបង្កាន់ដៃពន្ធយានយន្ត ត្រូវបង្កើតបង្កាន់ដៃនេះក្នុងប្រព័ន្ធអាស៊ីគូដានិងបោះពុម្ពចេញចំនួន ១(មួយ)ច្បាប់ រួចប្រគល់ជូនប្រតិវេទករ ដោយពុំតម្រូវឱ្យមានហត្ថលេខានិងបោះត្រាឡើយ។

## ឈ. ភារកិច្ចរបស់មន្ត្រីគយគ្រប់គ្រងស្តុកទំនិញ (Exit Note)

មន្ត្រីគយគ្រប់គ្រងស្តុកទំនិញ មានភារកិច្ចគ្រប់គ្រង និងប្រគល់ទំនិញដែលបានបំពេញកាតព្វកិច្ចពន្ធអាកររួចរាល់ ដែលមិនទាន់ដឹកជញ្ជូនយកចេញ ត្រូវអនុវត្តដូចខាងក្រោម÷

- លើកលែងមានការកំណត់ដោយឡែក ទំនិញដែលបានអនុញ្ញាតឱ្យដឹកជញ្ជូនចេញពីគយត្រូវបង្កើតប័ណ្ណដឹកជញ្ជូនទំនិញ ទោះបីជាទំនិញក្នុងមួយប្រតិវេទន៍គយត្រូវដឹកជញ្ជូនដោយមធ្យោបាយដឹកជញ្ជូនតែមួយក៏ដោយ។ ប័ណ្ណដឹកជញ្ជូនទំនិញមួយ មានសុពលភាពប្រើប្រាស់ត្រឹមតែមួយដងគត់ គិតចាប់ពីទីកន្លែងចេញដំណើររហូតដល់ទីកន្លែងគោលដៅ ដោយពុំតម្រូវឱ្យចុះហត្ថលេខានិងបោះត្រាដោយមន្ត្រីគយឡើយ
- បណ្ណដឹកជញ្ជូនអាចបង្កើតដោយប្រតិវេទករឬមន្ត្រីគយគ្រប់គ្រងស្តុកទំនិញ ដូចខាងក្រោម÷
    - ក្នុងករណីមានការស្នើសុំប័ណ្ណដឹកជញ្ជូនទំនិញដោយប្រតិវេទករ មន្ត្រីគយគ្រប់គ្រងស្តុកទំនិញត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃទិន្នន័យប័ណ្ណដឹកជញ្ជូន ធៀបនឹងមធ្យោបាយដឹកជញ្ជូនជាក់ស្តែង
    - ក្នុងករណីប្រតិវេទករពុំបានស្នើសុំបណ្ណដឹកជញ្ជូនជាមុន មន្ត្រីគយគ្រប់គ្រងស្តុកទំនិញត្រូវបង្កើតប័ណ្ណដឹកជញ្ជូនទំនិញ។
- បណ្ណដឹកជញ្ជូនទំនិញដែលបានពិនិត្យនិងអនុញ្ញាតដោយមន្ត្រីគយគ្រប់គ្រងស្តុកទំនិញ ត្រូវផ្តល់ជូនប្រតិវេទករក្នុងទម្រង់អេឡិចត្រូនិក។ ប្រសិនបើមានការស្នើសុំពីប្រតិវេទករ មន្ត្រីគយគ្រប់គ្រងស្តុកទំនិញអាចបោះពុម្ពប័ណ្ណដឹកជញ្ជូនទំនិញប្រគល់ជូនប្រតិវេទករ ដោយពុំតម្រូវឱ្យចុះហត្ថលេខានិងបោះត្រាឡើយ
- គ្រប់គ្រង តាមដាន និងចងក្រងទិន្នន័យនៃបញ្ជីសមតុល្យទំនិញដែលបានបំពេញកាតព្វកិច្ចពន្ធនិងអាកររួចរាល់ហើយមិនទាន់បានដឹកជញ្ជូនចេញពីគយ និងរៀបចំរបាយការណ៍សមតុល្យនេះប្រចាំខែ តាមការតម្រូវ។

## ញ. ភារកិច្ចរបស់មន្ត្រីគយគ្រប់គ្រងច្រកទ្វារ (Exit Gate)

មន្ត្រីគយគ្រប់គ្រងច្រកទ្វារ មានភារកិច្ចដូចខាងក្រោម÷

- ផ្ទៀងផ្ទាត់ការដឹកជញ្ជូនចេញពីទីកន្លែងសន្និធិ រួមមាន កំពង់ផែ ផែស្ងួត ឃ្លាំងទំនិញឬទីកន្លែងដែលទទួលបានការអនុញ្ញាតផ្សេងទៀត ដែលអនុវត្តដូចខាងក្រោម÷
  - ចំពោះទីតាំងមានបំពាក់បច្ចេកវិទ្យាច្រកទ្វារអេឡិចត្រូនិកគ្រប់គ្រងដោយរដ្ឋបាលគយ ការដឹកជញ្ជូនឆ្លងកាត់ច្រកទ្វារនឹងត្រូវផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិ
  - ចំពោះទីតាំងផ្សេងទៀត ការដឹកជញ្ជូនឆ្លងកាត់ច្រកទ្វារត្រូវផ្ទៀងផ្ទាត់ដោយមន្ត្រីគយ។
- ករណីរកឃើញភាពមិនប្រក្រតី ត្រូវរាយការណ៍ជូនប្រធានអង្គភាព ដើម្បីមានវិធានការបន្ត។

### ជ. ភារកិច្ចរបស់មន្ត្រីគយផ្តល់ជំនួយ (Help Desk)

មន្ត្រីគយផ្តល់ជំនួយ មានភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួល និងចង្អុលបង្ហាញដល់ម្ចាស់ទំនិញឬបុគ្គលទទួលបានសិទ្ធិជាតំណាង ក្នុងការរៀបចំនិងបំពេញប្រតិវេទន៍គយ ប្រសិនបើប្រតិវេទករស្នើសុំជំនួយ
- ផ្តល់ការប្រឹក្សាយោបល់ដល់ធុរជន និង សាធារណជន ពាក់ព័ន្ធនឹងនីតិវិធីគយ និងអាចផ្តល់ព័ត៌មានផ្សេងទៀត តាមលទ្ធភាព
- អង្គភាពគយនិងរដ្ឋាករនីមួយៗ ត្រូវបិទផ្សាយបញ្ជីឈ្មោះបច្ចុប្បន្នភាពមន្ត្រីគយផ្តល់ជំនួយ នៅបញ្ជរព័ត៌មាន។

### ឈ. ភារកិច្ចរបស់ប្រធានអង្គភាពបំពេញបែបបទគយ (Management)

ប្រធានអង្គភាពបំពេញបែបបទគយ មានភារកិច្ចដូចខាងក្រោម÷

- ទទួលខុសត្រូវទាំងស្រុងលើរាល់កិច្ចដំណើរការនៃការរាយការណ៍អំពីទំនិញ និងការបំពេញបែបបទបញ្ចេញទំនិញពីគយនៅអង្គភាពរបស់ខ្លួន
- រៀបចំចាត់ចែងឬកែសម្រួលសមាសភាពមន្ត្រីគយឱ្យទទួលបន្ទុកការងារតាមផ្នែកនីមួយៗ តាមស្ថានភាពជាក់ស្តែង ដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាពការងារ។ ប្រធានអង្គភាពបំពេញបែបបទគយអាចស្នើសុំបង្កើតគណនីប្រើប្រាស់ឬផ្លាស់ប្តូរមុខងារជូនមន្ត្រីគយក្រោមឱវាទ និងអាចស្នើសុំលុបគណនីប្រើប្រាស់ចេញពីប្រព័ន្ធ
- ពិនិត្យស្ថានភាពប្រតិវេទន៍ប្រចាំថ្ងៃ ដែលមន្ត្រីគយសាកសួរបានរាយការណ៍ជូន និងជំរុញប្រតិវេទករឱ្យរួសរាន់បញ្ចប់បែបបទរបស់ខ្លួនឱ្យបានឆាប់
